# អង្គការ អេហ្វ អេក កម្ពុជា
# បទដ្ឋានសីលធម៌
## FH Cambodia
## Ethical Standards for Suppliers and Contractors

ដៃគូ អ្នកផ្គត់ផ្គង់ ឬអ្នកម៉ៅការរបស់អង្គការ អេហ្វ អេក កម្ពុជាទាំងអស់ ដែលភ្ជាប់ទំនាក់ទំនងជាមួយអង្គការ អេហ្វ អេក កម្ពុជា តាមរយៈកិច្ចព្រមព្រៀង ឬកិច្ចសន្យាសេវា ត្រូវតែអាន ទទួលស្គាល់ និងចុះហត្ថលេខាលើទម្រង់បែបបទមួយនេះ។

All FH Cambodia partners, suppliers, or contractors who engage with FH Cambodia through a service agreement or contract must read, acknowledge, and sign on this form.

### គោលនយោបាយគាំពារ/ Safeguarding

អង្គការ អេហ្វ អេក កម្ពុជា ជឿថា មនុស្សរាល់គ្នាត្រូវបានបង្កើតឡើង ក្នុងរូបភាពនៃព្រះជាម្ចាស់ ហើយគួរតែទទួលបានការគោរព ក៏ដូចជាកិត្តិយសតាមរយៈគុណតម្លៃខាងក្នុងរបស់ពួកគេ ហើយផ្តោតយកចិត្តទុកដាក់ចំពោះវិធីសាស្រ្ត ក្នុងការសរសើរតម្កើងព្រះជាម្ចាស់។ គោលបំណងនៃគោលនយោបាយនេះ គឺដើម្បីការពារអ្នកទទួលផល រួមទាំងកុមារ និងជន ងាយរងគ្រោះទាំងអស់ពីគ្រោះថ្នាក់ផ្សេងៗ ដែលអាចកើតមានឡើងដោយសារការចូលរួមរបស់ពួកគេនៅក្នុងកម្មវិធីរបស់អង្គការ អេហ្វ អេក កម្ពុជា ។

FH Cambodia believes all people are made in the image of God and should be treated with respect, honored for their intrinsic value, and cared for in ways that glorify God. The purpose of this policy is to protect all beneficiaries, including children and all vulnerable populations, from any harm that may be caused due to their involvement with or through from FH Cambodia.

- ក្រុមហ៊ុនរបស់ខ្ញុំយល់ព្រមប្រកាន់ខ្ជាប់នូវគោលនយោបាយរបស់អង្គការ អេហ្វ អេក កម្ពុជា ដែលដាក់ចេញដោយអង្គការ អេហ្វ អេក កម្ពុជា ក៏ដូចជាគោលនយោបាយស្តីពីការការពារលើការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទ ព្រមទាំងការរំលោភបំពានលើអនីតិជន និងកុមារ។
- My company agrees to adhere to the FH Cambodia Policy, which sets out the FH Cambodia, the Protection Against Sexual Exploitation and the Abuse of Minors and Children.
- ខ្ញុំមិនដែលត្រូវបានចោទប្រកាន់ ឃាត់ឃាំងខ្លួន ឬផ្តន្ទាទោសពីបទល្មើសណាមួយ ដែលទាក់ទងនឹងការកេងប្រវ័ញ្ច ឬការរំលោភបំពានផ្លូវភេទ ឬការរំលោភបំពានលើកុមារ ដូចដែលមានចែងក្នុងគោលនយោបាយពាក់ព័ន្ធ និងគាំទ្រផ្សេងទៀតនោះទេ។
- I have never been charged, detained, or convicted of any offense in connection with the exploitation or sexual abuse or abuse of a child, as set forth in the Support and Related Policies.

## **គោលនយោបាយក្រមសីលធម៌/ Code of Conduct**

អង្គការ អេហ្វ អេក កម្ពុជា បដិសេធរាល់ការប្រព្រឹត្តទាំងអស់ ដែលប៉ះពាល់ដល់សុចរិតភាពរបស់អេហ្វ អេក ព្រមទាំងរាល់ទម្រង់នៃការកេងប្រវ័ញ្ច ការរើសអើង បៀតបៀនកេរ្តិ៍ខ្មាស ការសងសឹក ឬការរំលោភបំពាននៅក្នុងសហគមន៍។ គប្បីប្រព្រឹត្តចំពោះមនុស្សគ្រប់រូបដោយប្រកាន់ខ្ជាប់នូវភាពយុត្តិធម៌ ការគោរព និងប្រកបដោយសេចក្តីថ្លៃថ្នូរ តាមរយៈការស្វែងរកអំពីបញ្ហារសើបទាក់ទិននឹងវប្បធម៌ ទំនៀមទម្លាប់ និងប្រពៃណីក្នុងស្រុក។ យើងបញ្ចៀសរាល់ការប្រព្រឹត្តណា ដែលមិនអាចទទួលយកបាននៅក្នុងសហគមន៍ដែលយើងបម្រើ ឬនៅតាមទីកន្លែងជាក់លាក់ណាមួយ។
FH Cambodia refrains from all practices that undermine the integrity of FH including any form of exploitation, discrimination, harassment, retaliation, or abuse in the communities. Treat all people fairly and with respect and dignity, seeking to be sensitive to local cultures, customs, and traditions. We strive to avoid behaving in ways that are not acceptable in communities where we serve or in particular settings.

- ខ្ញុំយល់ព្រមគោរពតាមគោលនយោបាយក្រមសីលធម៌របស់អង្គការ អេហ្វ អេក កម្ពុជា នៅក្នុងករណីមានការដាក់ពាក្យស្នើសុំ ភាគីហត្ថលេខី ស្ថាប័ន ឬបុគ្គលិកតំណាងឱ្យក្រុមហ៊ុនរបស់ពួកគេ។
- I agree to respect the FH Cambodia code of conduct in the case of the application, the signatory, the institution, or the employee representing them.

## **គោលនយោបាយប្រឆាំងការក្លែងបន្លំ និងអំពើពុករលួយ / Anti-Fraud and Corruption**

អង្គការ អេហ្វ អេក កម្ពុជា ប្រកាន់ខ្ជាប់នូវគោលនយោបាយមិនអត់ឱនដាច់ខាត ចំពោះការក្លែងបន្លំ ឬអំពើពុករលួយ ហើយធានាបាននូវស្តង់ដារខ្ពស់បំផុតនៃការបង្ការ ការរកឃើញ និងការដោះស្រាយ។ រាល់ទម្រង់នៃការសូកប៉ាន់ គឺមិនអាចទទួលយកបានឡើយ ក៏ដូចជាការប្រើប្រាស់ឆានែលផ្សេងៗ ដើម្បីទទួលបាន អត្ថប្រយោជន៍ផ្ទាល់ខ្លួន ឬអាជីវកម្មដែលមិនស្របច្បាប់ សម្រាប់អតិថិជន ភ្នាក់ងារ អ្នកម៉ៅការ និងអ្នកផ្គត់ផ្គង់ ឬសូម្បីតែបុគ្គលិករបស់ពួកគេ ក៏ដូចជាមន្ត្រីសាធារណៈ ត្រូវបានហាមឃាត់យ៉ាងតឹងរ៉ឹង។ អង្គការ អេហ្វ អេក កម្ពុជា រំពឹងថា អ្នកលក់ទាំងអស់នឹងផ្តល់សេវាកម្មបានល្អ និងមានតម្លាភាព ក្នុងភាពជាដៃគូជាមួយ អង្គការ អេហ្វ អេក កម្ពុជា។
FH Cambodia has a zero-tolerance attitude towards fraud or corruption and maintains the highest standards of prevention, detection, and remediation. All forms of bribery are unacceptable, as well as the use of alternative channels to secure illegitimate private or business-related advantages for customers, agents, contractors and suppliers or their employees as well as public officers is strictly prohibited. FH Cambodia expects all vendors to maintain good services and be transparent as partnership with FH Cambodia.

- ក្នុងនាមជាអ្នកលក់ ខ្ញុំសូមប្រកាសថា តម្លៃទាំងអស់ដែលផ្តល់ជូនអង្គការ អេហ្វ អេក កម្ពុជា គឺមិនរួមបញ្ចូលកម្រៃជើងសារ អំណោយ និងសំណូកអ្វីឡើយ។
- As the vendor, I declare that all the prices provide to FH Cambodia is not included commission, gift, and bribes.

**គោលនយោបាយការពារអ្នករាយការណ៍/ Whistle-blower**

- ខ្ញុំយល់ព្រមថា ខ្ញុំនឹងរាយការណ៍នូវរាល់ការសង្ស័យ ឬការចោទប្រកាន់ណាមួយ ដែលពាក់ព័ន្ធនឹងការបំពានលើគោលការណ៍នេះ ស្របតាមនីតិវិធីដែលមានចែងនៅក្នុងគោលនយោបាយទាំងនោះ។
- I agree that I shall report any suspicions or allegations of violations of this policy in accordance with the procedures outlined in those policies.
- ខ្ញុំយល់ និងដឹងថា ខ្ញុំនឹងត្រូវសហការក្នុងការស៊ើបអង្កេតលើការបំពានគោលការណ៍នេះឱ្យបានពេញលេញ រួមទាំងខ្លួនខ្ញុំផ្ទាល់ផងដែរ ប្រសិនបើខ្ញុំត្រូវបានចោទប្រកាន់ពីបទប្រព្រឹត្តខុស ហើយឈានដល់ការស៊ើបអង្កេត។
- I understand that I shall cooperate fully in the investigation of this policy violation, including myself, if I am accused of misconduct and reach an investigation.

**ខ្ញុំបានទទួលស្គាល់ និងយល់ព្រមអនុវត្តដោយវិចារណញ្ញាណ និងគោលបំណងនៃគោលនយោបាយក្រមសីលធម៌ គោលនយោបាយគាំពារ គោលនយោបាយប្រឆាំងការបៀតបៀន និងគោលនយោបាយការពារអ្នករាយការណ៍របស់អង្គការ អេហ្វ អេក កម្ពុជា។ ទម្រង់បទដ្ឋាននេះនឹងមានសុពលភាពរយៈពេលមួយឆ្នាំបន្ទាប់ពីត្រូវបានចុះហត្ថលេខា។**

**I acknowledged and agreed to follow by the spirit and intent of the FH Cambodia Code of Conduct, Safeguarding, Anti-Harassment, and Whistle-blower policies. This form will be valid for one year after it has been signed.**

**ឈ្មោះ / Name** ........................................................................................................

**ហត្ថលេខា/ Signature ៖** ................................................ **កាលបរិច្ឆេទ/ Date ៖** ...............................

**ឈ្មោះក្រុមហ៊ុន/ Company Name ៖**.............................................................................................